# Orange County ដាក់ឲ្យប្រើប្រាស់ផែនទីសមធម៌ OC ដើម្បីដោះស្រាយវិសមភាព និងគម្លាតធនធាន

### ឧបករណ៍បង្កើតផែនទីជួយខោនធីបែងចែកធនធាន កាត់បន្ថយគម្លាតនៅក្នុងសហគមន៍ OC

Orange County កំពុងអនុវត្តវិធីសាស្ត្រដែលផ្តោតលើទិន្នន័យដើម្បីដោះស្រាយវិសមភាព និងគម្លាតផ្នែកធនធាន។ នៅថ្ងៃទី 14 ខែកក្កដា ខោនធីនឹងដាក់ឲ្យប្រើប្រាស់ឧបករណ៍បង្កើតផែនទីថ្មីដែលតាមដានគម្លាតផ្នែកសុខភាព និងសង្គមរបស់ Orange County។

អ្នកគ្រប់គ្រង **Andrew Do** ដែលជាប្រធានក្រុមប្រឹក្សាអ្នកគ្រប់គ្រងនៅ Orange County បានពន្យល់ថា "COVID-19 បានបង្កឲ្យមានវិសមភាពជាច្រើនផ្នែកសុខភាព និងសង្គម ដែលក្រុងនិងអង្គការក្នុងមូលដ្ឋានជាច្រើនមិនបានត្រៀមខ្លួននៅពេលជួបនឹងរោគរាតត្បាតកម្រិតខ្ពស់" ។ "ឧបករណ៍បង្កើតផែនទីសមភាព OC របស់យើងនឹងផ្តល់គោលដៅវាស់វែងដែលអាចសម្រេចបាន ដើម្បីបែងចែកធនធាន និងកាត់បន្ថយគម្លាតនៅក្នុងសហគមន៍របស់យើង។"

កាលពីខែឧសភា ឆ្នាំ 2020 គណៈកម្មការចំពោះកិច្ចធ្វើតេស្ត COVID-19 ដែលដឹកនាំដោយលោកប្រធាន Andrew Do និងអនុប្រធាន Doug Chaffee បានដឹកនាំទីភ្នាក់ងារគាំពារសុខភាពនៃ Orange County (Orange County Health Care Agency, HCA) ដើម្បីបង្កើតឧបករណ៍បង្កើតផែនទីសមធម៌ OC (OC Equity Map, OCEM) ។ គោលបំណងនៃគំនិតផ្តួចផ្តើមនេះគឺដើម្បីបង្កើតប្រព័ន្ធទិន្នន័យដែលជូនដំណឹងដល់អ្នកដឹកនាំ Orange County ស្ថាប័នរដ្ឋ/ឯកជន និងនិវាសនជន អំពីតំបន់ដែលរងការប៉ះពាល់អំពីហានិភ័យ នៃ COVID-19 ដែលកាន់តែកើនឡើង។

លោកអនុប្រធាន **Doug Chaffee**, ប្រចាំស្រុកទីបួនបាននិយាយថា "ផែនទីសមធម៌ OC វាស់វែងអំពីវឌ្ឍនភាពរបស់យើងដែលយើងបានធ្វើឡើងក្នុងពេលដែលសហគមន៍មានគោលដៅកែលម្អគុណភាពជីវិតសម្រាប់និវាសនជនគ្រប់គ្នានៅក្នុង Orange County" ។ "យើងសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារថែទាំសុខភាព OC និង Advance OC ចំពោះការដាក់ឲ្យប្រើប្រាស់ OCEM និងការផ្តល់មកយើងនូវឧបករណ៍ដ៏មានអំណាចដើម្បីសម្រេចគោលដៅនៃការបង្កើតសង្គមមួយដែលកាន់តែមានសមធម៌ និងសុខភាពល្អ។"

ដើម្បីជួយឲ្យ HCA កំណត់អត្តសញ្ញាណដើមហេតុនៃបញ្ហានៃគម្លាតដែលកើតឡើងថ្មីៗនៅក្នុង Orange County ដែលបានលេចចេញមកពីជំងឺរាតត្បាតនេះ ក្រុមប្រឹក្សាអ្នកគ្រប់គ្រងបានអនុម័ត [កិច្ចព្រមព្រៀងជាមួយ Advance OC] កាលពីខែកក្កដា ឆ្នាំ 2020 ដោយបានបង្កើតកិច្ចការដល់ អង្គការមិនរកប្រាក់ចំណេញនេះ ដើម្បីបង្កើតផែនទីសមធម៌ចាំបាច់ដើម្បីវឌ្ឍនភាពសង្គមរបស់ Orange County ដើម្បីក្តាប់បាននូវទិន្នន័យលទ្ធផលប្រជាជននៅក្នុងវិស័យទូលំទូលាយចំនួនបី៖ តម្រូវការជាមូលដ្ឋានរបស់មនុស្ស, មូលដ្ឋានគ្រឹះនៃសុខុមាលភាព និងឱកាស។

"ជម្រៅនៃទិន្នន័យនេះនឹងជួយបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ដៃគូរដ្ឋនិងឯកជនដើម្បីដោះស្រាយរួមគ្នានូវស្ថានភាពស្មុគស្មាញក្នុងសង្គមចាប់ពីឫសគល់នៃវិសមភាពចំពោះសុខភាព និងសុខុមាលភាព។ ប្រព័ន្ធនេះក៏គាំទ្រដល់បេសកកម្មរបស់ទីភ្នាក់ងារថែទាំសុខភាព OC ក្នុងការធ្វើការរួមគ្នាជាមួយសហគមន៍ ដើម្បីនាំមកនូវសេវាកម្មដែលប្រកបទៅដោយនិរន្តភាពនិងការឆ្លើយតប ដែលលើកកម្ពស់សុខភាពនិងសមធម៌របស់ប្រជាជន" នេះបើតាមការអះអាងរបស់នាយកទីភ្នាក់ងារ HCA លោក Clayton Chau, ដែលជា MD, PhD, និងមន្ត្រីសុខាភិបាលប្រចាំខោនធី។

នៅក្រោមដំណាក់កាលទី I, Advanced OC បានប្រើប្រាស់សំណុំទិន្នន័យជំរឿនឆ្នាំ 2010 ដើម្បីបង្ហាញពីស្ថានភាពវង្វេងភាពសង្គមរបស់ Orange County។ ព្រឹត្តិការណ៍ដាក់ឲ្យប្រើប្រាស់នេះនឹងធ្វើឡើងនៅថ្ងៃទី 14 ខែកក្កដា នៅឧទ្យាន Mile Square Park សម្រាប់មន្ត្រីជាប់ឆ្នោត មន្ត្រីក្រុង សមាជិកគណៈកម្មការ អង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតពីចំណោមសាធារណជន។ ដំណាក់កាលទី II នឹងប្រើប្រាស់ទិន្នន័យជំរឿនឆ្នាំ 2020 ហើយនឹងត្រូវបានឧបត្ថម្ភដោយវិស័យឯកជន។

ខោនធីនឹងផ្តល់សិទ្ធិចូលប្រើប្រាស់កម្មវិធី OCEM ទៅសាធារណជនដោយឥតគិតថ្លៃ ហើយនឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការវាស់ស្ទង់ តាមដាន និងកំណត់បង្ហាញវិសមភាពនៅក្នុងសហគមន៍ដែលមានភាពច្បាស់លាស់ក្នុងតំបន់ជុំវិញ រួមទាំងការកំណត់អត្តសញ្ញាណឫសគល់នៃបញ្ហា ការយល់ដឹងពីកត្តាកំណត់របស់សង្គម និងការជូនដំណឹងពីយុទ្ធសាស្រ្តដើម្បីធ្វើឱ្យសុខភាពនិងសុខុមាលភាពរបស់អ្នកដែលមានលំនៅដ្ឋានក្នុង Orangae County កាន់តែបានល្អប្រសើរ។

“AdvanceOC មានកិត្តិយសក្នុងការធ្វើការជាមួយខោនធី Orange និង HCA លើគំនិតផ្តួចផ្តើមសំខាន់នេះ។ យើងមានមោទកភាពក្នុងការបង្ហាញប្រព័ន្ធនេះទៅ សហគមន៍ ដើម្បីកែលម្អយុទ្ធសាស្រ្តដោះស្រាយបញ្ហាគម្លាតសង្គម និងសុខភាព ដែលតម្រែតម្រង់ទិសពីបញ្ហាសមភាពដោយពឹងផ្អែកលើទិន្នន័យនេះឱ្យបានកាន់តែប្រសើរ។ ភាពជាដៃគូរបស់យើងជាមួយ HCA ឆ្លុះបញ្ចាំងពីរបៀបដែលវិទ្យាសាស្រ្តទិន្នន័យអាចជួយឱ្យអង្គភាពសម្រេចបាននូវឥទ្ធិពលកាន់តែអស្ចារ្យ។ Katie Kalvoda ដែលជានាយក និងប្រធានក្រុមប្រឹក្សាភិបាលរបស់ AdvanceOC បាននិយាយថា “យើងសង្ឃឹមថាឃើញកិច្ចសហការកាន់តែច្រើននៅក្នុងសហគមន៍ ហើយមានក្តីរំភើបរីករាយដែលប្រព័ន្ធនេះអាចជួយសម្របសម្រួលការសន្ទនាសំខាន់ៗជុំវិញបញ្ហាសមភាពបាន” ។

ដើម្បីសាកល្បង និងស្វែងយល់ពីសមត្ថភាពខាងផ្នែកវិភាគថ្មីនេះ HCA បាននឹងកំពុងប្រើប្រាស់ប្រព័ន្ធ OCEM នៅក្នុងការឆ្លើយតបរបស់ខ្លួននឹងជំងឺ COVID-19 រួមទាំងការធ្វើតេស្ត ការបែងចែកនិងការចែកចាយវ៉ាក់សាំង ព្រមទាំងយុទ្ធសាស្រ្តបន្ធូរបន្ថយផ្សេងទៀត។ ប្រព័ន្ធនេះក៏ផ្តល់ជូនផែនទីបង្ហាញផ្លូវសម្រាប់ភាពជាដៃគូឯកជននិងសាធារណៈផងដែរ ដើម្បីផ្តល់មូលនិធិដល់គំនិតផ្តួចផ្តើមដែលស្វែងរកវិធីសាស្រ្តបែបសហការក្នុងការដោះស្រាយស្ថានភាពសង្គមដែលស្មុគស្មាញចាប់ពីឫសគល់នៃវិសមភាពក្នុងផ្នែកសុខភាពនិងសុខុមាលភាព។

###